រស្មីកម្ពុជា
ចេញប្រចាំថ្ងៃ

ថ្ងៃអាទិត្យ-ច័ន្ទ ទី១០-១១ ខែកញ្ញា ឆ្នាំ២០០៦

# បុគ្គលិកមជ្ឈមណ្ឌលសិទ្ធិមនុស្ស ចោទលោកកឹមសុខាថាពុករលួយ

***ភ្នំពេញ : បុគ្គលិកនៃមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា បានចោទប្រកាន់លោកកឹម សុខា ប្រធានមជ្ឈមណ្ឌលនេះ ថាបានប្រព្រឹត្តអំពើពុករលួយ កេងប្រវ័ញ្ចថវិកាជំនួយពីសហរដ្ឋអាមេរិក ។***

***ពាក្យបណ្ដឹងត្រូវបានធ្វើឡើង*** និងផ្ញើទៅកាន់បណ្ឌិតហ៊ាន វិទ្ធិ ប្រធានអង្គការស្រាវជ្រាវកម្ពុជា (CNRO) កាលពីថ្ងៃ៨ខែកញ្ញា ដោយមានស្នាមមេដៃនិងឈ្មោះអតីតបុគ្គលិក និងបុគ្គលិកកំពុងបម្រើការងារនៅមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ដោយភ្ជាប់មកជាមួយនូវឯកសារគាំទ្រចំពោះការចោទប្រកាន់ថាលោកកឹម សុខា បានប្រព្រឹត្តអំពើលុករលួយ ។ ការចោទប្រកាន់ទាំងនោះរួមមាន ការកិបកេងប្រាក់ខែបុគ្គលិក ការកិបកេងកាតទូរស័ព្ទរបស់បុគ្គលិក ការកិបកេងថវិកាពីរបបឧបត្ថម្ភប្រចាំថ្ងៃ ថ្លៃធ្វើដំណើរនិងការស្នាក់នៅរបស់ប្រជាពលរដ្ឋចូលរួមក្នុងវគ្គបណ្ដុះបណ្ដាលអំពីពលរដ្ឋវិជ្ជា ការលាក់លៀមគម្រោងថវិកា ការក្លែងបន្លំឯកសារ និងការប្រឌិតបេសកកម្ម ដើម្បីកិបកេងថវិកាក្នុងគម្រោង និងគ្រួសារនិយមជាដើម ។ នៅក្នុងពាក្យបណ្ដឹងដែលសុំឱ្យអង្គការស្រាវជ្រាវកម្ពុជាជួយរកយុត្តិធម៌ បាននិយាយថា នៅក្នុងផ្ទៃក្នុងមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ដែលកំពុងតែដឹកនាំដោយលោកកឹម សុខា គឺបាននិងកំពុងកើតមាននូវភាពមិនប្រក្រតីជាច្រើនករណី នាំឱ្យមានការរំលោភសិទ្ធិមនុស្សយ៉ាងស្ងៀមស្ងាត់ ប៉ះពាល់ដល់បុគ្គលយើងខ្ញុំម្នាក់ៗយ៉ាងខ្លាំង ព្រោះតែលោកកឹម សុខា កេងប្រវ័ញ្ចថវិកាជំនួយរបស់សហរដ្ឋអាមេរិកយកមកដាក់ប្រយោជន៍បុគ្គលខ្លួនឯង និងបក្ខពួកញាតិមិត្តរបស់ខ្លួនឯង ដែលប្រាក់ជំនួយនេះគឺសម្រាប់ផលប្រយោជន៍ដល់ប្រជាពលរដ្ឋខ្មែរ ។

ឯកសារបានពន្យល់ថា ការដកប្រាក់បៀវត្សរ៍ប្រចាំខែរបស់យើងខ្ញុំកន្លងមក ពុំមានផ្ដល់វិក្កយបត្រមួយច្បាប់ៗមកសាមីខ្លួន ឬក៏ពុំឱ្យសាមីខ្លួនបានឃើញទេ ។ រាល់ការបើកប្រាក់បៀវត្សរ៍ប្រចាំខែ យើងម្នាក់ៗបានចុះហត្ថលេខាជាអ្នកទទួលលើក្រដាសធម្មតាមួយសន្លឹក (ទំហំ A4) ចំនួនមួយច្បាប់គត់ ដែលពុំមែនជាវិក្កយបត្រមានគល់និងចុងសន្លឹកឡើយ ហើយក្នុងខណៈពេលទទួលប្រាក់ អ្នកប្រគល់ពុំបានចុះហត្ថលេខានៅចំពោះមុខអ្នកទទួលទេ ។

ក្រៅពីនេះ បុគ្គលិកមជ្ឈមណ្ឌលសិទ្ធិមនុស្សក៏បានចោទប្រកាន់លោកកឹម សុខា អំពីការកាត់ប្រាក់ខែផងដែរ ។ ពាក្យបណ្ដឹងនិយាយថា តាមគម្រោងថវិកាផ្លូវការដោយយល់ព្រមពីម្ចាស់ជំនួយ គឺប្រាក់ខែសម្រាប់តួនាទីជាប្រធានការិយាល័យតំបន់មានចំនួន៥០០ដុល្លារ ប៉ុន្តែការពិតជាក់ស្ដែងប្រធានការិយាល័យតំបន់ខ្លះទទួលបានតែ៣៥០ដុល្លារ ហើយខ្លះទៀតទទួលបានតែ៣០០ដុល្លារក្នុងមួយខែ ។ ចំណែកមន្ត្រីជំនួយការផ្នែកអប់រំនៅការិយាល័យតំបន់បានចុះហត្ថលេខាទទួល២០០ដុល្លារអាមេរិកក្នុងមួយខែ តែការពិតសាមីខ្លួនទទួលបានតែ១៥០ដុល្លារប៉ុណ្ណោះ ។

លោកកឹម សុខា ក៏បានទទួលរងការចោទប្រកាន់ផងដែរថា បានលាក់លៀមនូវថវិកាគម្រោង ដោយមិនអនុញ្ញាតឱ្យអ្នកប្រតិបត្តិការគម្រោងនីមួយៗបានដឹងឡើយ ។ ជាមួយគ្នានេះ ការក្លែងបន្លំហត្ថលេខា ដើម្បីកិបកេងថវិកាក្នុងគម្រោងនិងការប្រឌិតបេសកកម្មក៏បានកើតមានផងដែរនៅក្នុងមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ។

ពាក្យបណ្ដឹងនេះបានចុះហត្ថលេខាដោយមនុស្សចំនួន១៦នាក់ ដោយក្នុងនោះរួមមានលោកញ៉ែម វណ្ណថន និងលោកបណ្ឌិត ឈឹម-ផលវរុណផងដែរ ។

លោកកឹម សុខាវិញបាននិយាយថា នេះគឺជាសិទ្ធិតវ៉ារបស់បុគ្គលិកទាំងនេះ ។

នៅពេលដែលចោទសួរថាៗ ថាតើពិតជាមានករណីពុករលួយដូចដែលបុគ្គលិកបានចោទប្រកាន់ឬយ៉ាងណានោះ លោកកឹម សុខា មិនបានឆ្លើយឡើយ ដោយគ្រាន់តែនិយាយថា រឿងនេះមានឬមិនមាននោះ គឺស្រេចនៅលើម្ចាស់ជំនួយ ។

ប៉ុន្តែលោកកឹម សុខាបានពន្យល់អំពីហេតុផលនៃការប្ដឹងនេះថា បណ្ដាលមកពីម្ចាស់ជំនួយបានសម្រេចកាត់បន្ថយបុគ្គលិក ហើយពួកគេទាំងនោះមានការមិនសប្បាយចិត្ត ។ យើងក៏មានការអាណិតដល់ពួកគាត់ដែរ ៕

គន្ធា